**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៤៤៣ ព.ណ.សរ.ចា

ថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

# សេចក្ដីជូនដំណឹង

យោងលិខិតលេខ Z-2022/10605253/34664724 ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០២២ របស់ស្ថានទូតសាធារណរដ្ឋទួរគីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលិខិតរបស់អគ្គនាយកដ្ឋានកិច្ចព្រមព្រៀងអន្តរជាតិ និងកិច្ចការសហគមអឺរ៉ុប នៃក្រសួងពាណិជ្ជកម្ម របស់សាធារណរដ្ឋទួរគី ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការប្រើប្រាស់ឈ្មោះប្រទេសទួរគី (Türkiye)។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ឲ្យបាន ជ្រាបថា អគ្គនាយកដ្ឋានកិច្ចព្រមព្រៀងអន្តរជាតិ និងកិច្ចការសហគមអឺរ៉ុប (Directorate General of International Agreements and the EU Affairs) នៃក្រសួងពាណិជ្ជកម្មរបស់សាធារណរដ្ឋទួរគី បានចេញនូវការប្រើប្រាស់ឈ្មោះប្រទេសក្នុងការបញ្ជាក់លើកស្លាកដើមកំណើតទំនិញ និង Movement Certificates ក៏ដូចជាឯកសារនាំចេញផ្សេងៗ ត្រូវធ្វើការផ្លាស់ប្តូរឈ្មោះពី "Turkey","Türkei" និង "Turquie" ទៅជា "Türkiye" វិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តឲ្យមានប្រសិទ្ធិភាពតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ។

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469